# មហាសន្និបាតរបស់សហគមន៍អភិវឌ្ឍន៍កសិកម្មអង្គរដងទង់

កាលពីថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០០៩ នៅភូមិត្រពាំងឬស្សី ឃុំដំណាក់សុក្រំ ស្រុកដងទង់ ខេត្តកំពត សេដាក បានប្រារព្ធធ្វើមហាសន្និបាតបង្កើតសហគមន៍អភិវឌ្ឍន៍កសិកម្មអង្គរដងទង់ ដោយមានសមាជិកចូលរួមចំនួន ៥៧ នាក់ (ស្ត្រី ៣៥ នាក់) ។ ក្រៅពីនេះក៏មានវត្តមានចូលរួមពីសំណាក់ ប្រធាននាយកដ្ឋានផ្សព្វផ្សាយកសិកម្មក្រសួងកសិកម្ម ប្រធានមន្ទីរកសិកម្មខេត្ត ប្រធានការិយាល័យកសិកម្មស្រុងដងទង់ ប្រធានភូមិត្រពាំងឬស្សី និងប្រធានអង្គការ សេដាក ផងដែរ ។

មហាសន្និបាតនេះធ្វើឡើងក្នុងគោលបំណងដើម្បីៈ

- ពិភាក្សា និងសម្រេចលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍
- បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការត្រួតពិនិត្យ
- ចុះឈ្មោះសមាជិកសហគមន៍ ប្រមូលភាគហ៊ុន និងប្រាក់សមាជិកភាព

ជាលទ្ធផល អង្គមហាសន្និបាតបានសំរេចដាក់ឈ្មោះសហគមន៍នេះថា **សហគមន៍អភិវឌ្ឍន៍កសិកម្មអង្គរដងទង់** ហៅកាត់ថា **ស.អ.ដ**។ ចំពោះទីតាំង អង្គមហាសន្និបាតក៏បានសំរេចជ្រើសរើសយកទីតាំងភូមិត្រពាំងឬស្សី ឃុំដំណាក់សុក្រំ ស្រុកដងទង់ ខេត្តកំពត ធ្វើជាទីតាំងសហគមន៍។ ក្រៅពីនេះអង្គមហាសន្និបាតក៏បានធ្វើការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការត្រួតពិនិត្យតាមរយៈការលើកដៃគាំទ្រ ដោយយកសំលេងគាំទ្រលើសលប់។

គួរជំរាបជូនថា គោលបំណងរបស់សហគមន៍គឺដើម្បីជួយសម្របសម្រួលអំពីការដឹកនាំ និងគ្រប់គ្រងលើសកម្មភាព ផលិតកម្ម អាជីវកម្ម ការទិញលក់ ផលិតផល ជាពិសេសស្រូវអង្គរ ការផ្តល់ឥណទាន ផ្តល់សេវាកម្មបណ្តុះបណ្តាល និងផ្សព្វផ្សាយបច្ចេក ទេសកសិកម្មក្នុងទិសដៅបង្កើនប្រាក់ចំណូលគ្រួសារ ប្រកួតប្រជែងការពារផលិតផលក្នុងស្រុកប្រកប ដោយតម្លាភាព និងយុត្តិធម៌។

